# កិច្ចការបញ្ចប់មេរៀនទី១ សាលាកុមារមេត្រី

➢ អំណាន : ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

សាលារៀនខ្ញុំ ជាសាលាកុមារមេត្រី ។

សាលារៀននេះសង់លើទីទួល មានបរិវេណធំទូលាយ និងរបងព័ទ្ធជុំវិញ ។ ក្នុងបរិវេណសាលារៀន មានអគារបីខ្នង ដប់ប្រាំបីបន្ទប់ ។ នៅក្នុងទីធ្លា មានដងទង់ជាតិ សួនច្បារ សួនកុមារ ទីលានកីឡា និងដើមឈើធំៗ ។ នៅខាងក្រោមអគារ មានសួនជីវៈចម្រុះ សួនបន្លែ និងបង្គន់អនាម័យសម្រាប់សិស្សប្រុស ស្រីផ្សេងពីគ្នា ។ ក្នុងបន្ទប់នីមួយមានតុ កៅអី ក្តារខៀន តាមជញ្ជាំងមានរូបភាព ពាក្យស្លោក និងមានតាំងស្នាដៃសិស្ស ។ល។ សាលារៀនខ្ញុំស្អាតគ្មានសំរាម និងមានពណ៌បៃតងស្រស់បំព្រងជានិច្ច ។

សិស្សទាំងអស់ពេញចិត្តនឹងការសិក្សានៅក្នុងសាលារៀននេះណាស់ ។ នៅចុងឆ្នាំពួកគេបានឡើងថ្នាក់ទាំងអស់គ្នា ហើយគ្មានសិស្សបោះបង់ចោលការសិក្សាឡើយ ។

ចូរគូសសញ្ញា √ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើសាលារៀននេះមានបរិវេណដូចម្តេច ?

☐ ក. តូច ☐ ខ. ចង្អៀត ☐ គ. ធំទូលាយនិងរបងព័ទ្ធជុំវិញ

២. តើក្នុងបរិវេណសាលារៀននេះ មានអគារប៉ុន្មានខ្នង ?

☐ ក. មួយខ្នង ☐ ខ. ពីរខ្នង ☐ គ. បីខ្នង

៣. តើសាលារៀននេះ មានប៉ុន្មានបន្ទប់ ?

☐ ក. ដប់ប្រាំមួយបន្ទប់ ☐ ខ. ដប់ប្រាំពីរបន្ទប់ ☐ គ. ដប់ប្រាំបីបន្ទប់

៤ តើមុនចូលរៀន សិស្សទាំងអស់តែងជួបជុំគ្នានៅណា ?

☐ ក. មុខសួនច្បារ ☐ ខ. នៅមុខខ្លោងទ្វារសាលា ☐ គ. នៅដងទង់ជាតិ

៥. ចូររកបដិសព្ទនឹងពាក្យ " ទូលាយ " ។

☐ ក. រលាយ ☐ ខ. ចង្អៀត ☐ គ. សម្បើម

LIVEWORKSHEETS

➢ <u>សំណេរ</u>

១. ចូរពន្យល់ពាក្យខាងក្រោម ។

- កុមារមេត្រី(   )..........................................................................................។
- ពាក្យស្លោក(   )..........................................................................................។

២. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោម ឱ្យបានត្រឹមត្រូវ ។

| ដងទង់ជាតិ | បៃតង | មេត្រី | សំរាម | ព័ទ្ធជុំវិញ |
|---|---|---|---|---|

ក. សាលារៀនខ្ញុំ ជាសាលារៀនកុមារ...........................។

ខ. សាលារៀននេះ មានបរិវេណធំទូលាយ និងរបង...............។

ខ. នៅក្នុងទីធ្លាសាលាមាន...............សួនច្បារ សួនកុមារ ទីលានកីឡា និងដើមឈើធំៗ ។

គ. សាលារៀនខ្ញុំស្អាតគ្មាន..................និងមានពណ៌....................ស្រស់បំព្រងជានិច្ច ។

៣. ចូររៀបពាក្យ ឬកន្សោមពាក្យខាងក្រោមទៅជាល្បះ ឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| ដើម្បី | ខិតខំ | រៀន | ក្លាយ | គ្រូបង្រៀន ។ | ខ្ញុំ |

..........................................................................................................................

| | | | | | |
|---|---|---|---|---|---|
| ស្រឡាញ់ | នេះ | ខ្ញុំ | សាលារៀន | ណាស់ | ខ្លាំង |

..........................................................................................................................

| | | | | | |
|---|---|---|---|---|---|
| សាលារៀន | គ្មាន | ខ្ញុំ | ស្អាត | ទេ ។ | សំរាម |

..........................................................................................................................

LIVEWORKSHEETS